*បកប្រែក្រៅផ្លូវការ*

# ស្តង់ដាទីក្រុងទេសចរណ៍ស្អាតអាស៊ាន

## (គោលការណ៍ណែនាំ)


**រៀបចំដោយ**

**ក្រសួងទេសចរណ៍កម្ពុជា**

# ស្តង់ដាទីក្រុងទេសចរណ៍ស្អាតអាស៊ាន—លក្ខណៈវិនិច្ឆ័យ

## ១)-តារាងវាយតម្លៃលើសូចនាករចំនួន០៥ នៃការគ្រប់គ្រងបរិស្ថាន

| ការគ្រប់គ្រងបរិស្ថាន | | តម្រូវការនៃសូចនាករសំខាន់ៗ | លក្ខណៈវិនិច្ឆ័យ | ភស្តុតាងសម្រាប់លក្ខណៈវិនិច្ឆ័យ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|---|---|---|
| ១ | ផែនការរៀបចំទីក្រុង | តើក្រុងបានប្រើប្រាស់ជំនាញរបស់ខ្លួនក្នុងការរៀបចំទីក្រុង និងការអនុវត្តគម្រោងតាមផែនការនោះដែរឬទេ? | តើមានផែនការមេនៃការប្រើប្រាស់ដីសម្រាប់ទីក្រុង? | បង្ហាញភស្តុតាង/វត្តមាននៃអាជ្ញាធរក្រុងដែលទទួលបន្ទុកនគរូបនីយកម្ម (កុងត្រា, សម្លេង...) និងរក្សាទុកនូវឯកសារផែនការមេប្រើប្រាស់ដីសម្រាប់ទីក្រុង (ផ្តល់ឯកសារយោង) | បាទ<br>ទេ | ☐<br>☐ |
| | | | តើបានប្រតិបត្តិទៅតាមផែនការមេនោះដែរឬទេ? | គួរអនុម័តចេញជាក្រិត្យច្បាប់មួយរបស់ក្រុងដើម្បីជាតឹកតាងមានសុពលភាពក្នុងការបង្កើនកម្លាំងបន្ថែមទៅលើផែនការ | បាទ<br>ទេ | ☐<br>☐ |
| | | | តើទីក្រុងត្រូវបានបែងចែកច្បាស់លាស់ទៅតាមផែនការបែងចែកតំបន់ឬទេ? | ផ្តល់នូវផែនការបែងចែកតំបន់តាមដំណាក់កាល និងពេលវេលាកំណត់ និងបង្ហាញលទ្ធផលនៃដំណើរការបែងចែកតំបន់ | បាទ<br>ទេ | ☐<br>☐ |
| | | | តើមានផែនការរៀបចំការធ្វើដំណើរសម្រាប់ទីក្រុងដែរ ឬទេ? | ផ្តល់ផែនការដឹកជញ្ជូនសម្រាប់ការដឹកជញ្ជូនឯកជន និងសាធារណៈ | បាទ<br>ទេ | ☐<br>☐ |
| | | | តើទិដ្ឋភាពបរិស្ថានត្រូវបានបញ្ចូលក្នុងផែនការឬទេ? | បង្ហាញវត្តមាននៃទិដ្ឋភាពបរិស្ថានមាននៅក្នុងផែនការ | បាទ<br>ទេ | ☐<br>☐ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | តើទិដ្ឋភាពបរិស្ថានទាំងនេះត្រូវបានអនុវត្ត ឬទេ? | បង្ហាញនូវការបន្ថែមកម្លាំង និងការអនុវត្តនៃនៃទិដ្ឋភាពបរិស្ថានទាំងនេះ | បាទ<br>ទេ | ☐<br>☐ |
| ២ | **បទបញ្ញត្តិស្ដីពីបរិស្ថាន** | តើគោលការណ៍បរិស្ថានត្រូវបាននិងកំពុងអនុវត្តក្នុងទីក្រុង? | តើបទបញ្ញត្តិស្ដីពីបរិស្ថានអាចត្រួតពិនិត្យលើដំណើរប្រតិបត្តិការនៃអាជីវកម្មទេសចរណ៍ដែរ ឬទេ? | បង្ហាញភស្តុតាងនៃភាពនៅមាននៃគោលការណ៍បរិស្ថានដែលត្រួតពិនិត្យលើដំណើរប្រតិបត្តិការនៃអាជីវកម្មទេសចរណ៍ | បាទ<br>ទេ | ☐<br>☐ |
| | | | តើទាំងនេះត្រូវបានប្រតិបត្តិក្នុងទីក្រុង ឬទេ? | បង្ហាញភស្តុតាងនៃវត្តមាននៃវិធានការផ្តោតលើការប្រតិបត្តិលើគោលការណ៍បរិស្ថានក្នុងទីក្រុង និងភស្តុតាងនៃការអនុវត្ត (គួរផ្តល់នូវរបាយការណ៍) | បាទ<br>ទេ | ☐<br>☐ |
| ៣ | **ការបំពុល** | តើទីក្រុងបានប្រយុទ្ធប្រឆាំងនឹងការបំពុលបរិស្ថាន? | តើបទដ្ឋានគុណភាពទឹកត្រូវបានរៀបចំដោយអាជ្ញាធរ ឬទេ? | បង្ហាញភស្តុតាងនៃភាពនៅមាននៃសេចក្តីសម្រេចរបស់អាជ្ញាធរស្តីពីគុណភាពទឹក (ទឹកសាប, ទឹកសមុទ្រ, ទឹកផឹក) ត្រួតពិនិត្យ និងបទដ្ឋាន | បាទ<br>ទេ | ☐<br>☐ |
| | | | តើទាំងនេះត្រូវបានអនុវត្តក្នុងទីក្រុង ឬទេ? | ផ្តល់បញ្ជីនៃវិធានការដាក់ចេញដោយអាជ្ញាធរពាក់ព័ន្ធដើម្បីត្រួតពិនិត្យបទដ្ឋានគុណភាពទឹក | បាទ<br>ទេ | ☐<br>☐ |
| | | | តើគុណភាពទឹកក្នុងទីក្រុងស្ថិតក្នុងបទដ្ឋានដែលបានកំណត់ ឬទេ? | ផ្តល់តារាងពេល និងលទ្ធផលនៃការត្រួតពិនិត្យគុណភាពទឹកដែលបញ្ជាក់ដោយអាជ្ញាធរពាក់ព័ន្ធ | បាទ<br>ទេ | ☐<br>☐ |
| | | | តើបទដ្ឋានគុណភាពខ្យល់ត្រូវបានកំណត់ដោយអាជ្ញាធរក្នុងទីក្រុងដែរឬទេ? | បង្ហាញភស្តុតាងនៃភាពនៅមាននៃសេចក្តីសម្រេចរបស់អាជ្ញាធរស្តីពីការត្រួតពិនិត្យគុណភាពខ្យល់ និងបទដ្ឋាន (ស្តង់ដាក្នុងស្រុក) ព្រមទាំងផ្តល់លទ្ធផលនិងតារាងពេលនៃការធ្វើពិសោធន៍ចង់ដឹង | បាទ<br>ទេ | ☐<br>☐ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | ដែលបញ្ជាក់ដោយអាជ្ញាធរពាក់ព័ន្ធ | | |
| | | | តើទាំងនេះត្រូវបានអនុវត្តក្នុងទីក្រុង ឬទេ? | ផ្តល់បញ្ជីនៃវិធានការដាក់ចេញដោយអាជ្ញាធរពាក់ព័ន្ធដើម្បីត្រួតពិនិត្យបទដ្ឋានគុណភាពខ្យល់ | បាទ<br>ទេ | ☐<br>☐ |
| | | | តើគុណភាពខ្យល់ និងគុណភាពទឹកត្រូវបានប្រកាសផ្សព្វផ្សាយជាសាធារណៈ ឬទេ? | ផ្តល់របាយការណ៍ជាប្រចាំតាមពេលកំណត់ស្តីពីគុណភាពខ្យល់ និងគុណភាពទឹកក្នុងទីក្រុង និងបង្ហាញភស្តុតាងអំពីប្រភេទនៃប្រព័ន្ធព័តមានសម្រាប់ប្រកាសផ្សាយ (ទូរទស្សន៍, កាសែត...) | បាទ<br>ទេ | ☐<br>☐ |
| | | | តើអាជ្ញាធរមានរៀបចំនូវវិធានការដើម្បីកាត់បន្ថយការបំពុលបរិស្ថានខ្យល់ដែរឬទេ? ដូចជាគំនិតផ្តួចផ្តើមកាត់បន្ថយការស្ទះចរាចរណ៍ ឧទាហរណ៍ៈ បំលែងការប្រើប្រាស់ប្រេង | ផ្តល់បញ្ជីនៃវិធានការដាក់ចេញដោយអាជ្ញាធរពាក់ព័ន្ធដើម្បីត្រួតពិនិត្យ និងបន្ធូរស្រាលការបំពុលបរិស្ថានខ្យល់ (ឧទាហរណ៍ ការស្ទះចរាចរ ការផ្តើមគំនិតកាត់បន្ថយ, ឧបករណ៍ បម្លែងសារធាតុគីមី, ការប្រើប្រាស់ប្រេងឥន្ធនះ យុទ្ធនាការផ្សព្វផ្សាយការយលើដឹង...) | បាទ<br>ទេ | ☐<br>☐ |
| | | | តើទាំងនេះត្រូវបានអនុវត្តក្នុងទីក្រុង ឬទេ? | ផ្តល់ភស្តុតាងនៃការអនុវត្តនៃវិធានការដើម្បីបន្ធូរស្រាលការបំពុលបរិស្ថានខ្យល់ | បាទ<br>ទេ | ☐<br>☐ |
| | | | តើអាជ្ញាធរមានរៀបចំណែនាំវិធានការ ដើម្បីកាត់បន្ថយការបំពុល បរិស្ថានសម្លេងដែរឬទេ? | បង្ហាញភស្តុតាងនៃភាពនៅមាននៃសេចក្តីសម្រេចរបស់អាជ្ញាធរ និងវិធានការ ដើម្បីត្រួតពិនិត្យការបំពុលបរិស្ថានសម្លេង | បាទ<br>ទេ | ☐<br>☐ |
| | | | តើទាំងនេះត្រូវបានប្រតិបត្តិក្នុងទីក្រុង | ផ្តល់ភស្តុតាងនៃការអនុវត្តនៃវិធានការដើម្បីបន្ធូរស្រាលការបំពុលបរិស្ថានសម្លេង (តឹកតាង មាន | បាទ | ☐<br>☐ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | ដូចជា: បញ្ជីនៃការប្ដឹងតវ៉ាអំពីការបំពុលបរិស្ថាន សម្លេង ការបាំងជញ្ជាំងដើម្បីកាត់បន្ថយ សម្លេង ការដាក់បម្រាមលើប្រភេទយានយន្ត មួយចំនួនក្នុងទីក្រុង សម្រាប់វេលាម៉ោងជាក់លាក់ខ្លះ...) | ទេ | |
| ៤ | **មធ្យោបាយធ្វើដំណើរដែលគិតគូរពីបរិស្ថាន** | តើអាជ្ញាធរបានអនុវត្តវិធានការពាក់ព័ន្ធនឹងមធ្យោបាយដឹកជញ្ជូនដែលគិតគូរដល់បរិស្ថាន? | តើមានប្រព័ន្ធដឹកជញ្ជូនសាធារណៈក្នុងទីក្រុង ដែរឬទេ? | ផ្ដល់ផែនទីចង្អុលបង្ហាញអំពីប្រព័ន្ធដឹកជញ្ជូនសាធារណៈ ក្នុងទីក្រុង (ឧទាហរណ៍ ដូចជា ឡានក្រុង រថក្រោមដី អយរថអគ្គិសនី តាក់ស៊ីទោចក្រយានសាធារណៈ រថភ្លើង...) | បាទ<br>ទេ | ☐<br>☐ |
| | | | តើអាជ្ញាធរបានណែនាំអំពីការធ្វើដំណើរជាសាធារណៈដែលគិតគូរដល់បរិស្ថានដែរឬទេ? (យន្តការត្រួតពិនិត្យការបំពុល) | បង្ហាញភស្តុតាងដែលថាការដឹកជញ្ជូនសាធាណៈបានប្រើប្រាស់ប្រព័ន្ធរក្សាបរិស្ថាន (ឧទាហរណ៍ ដូចជាវិធានការត្រួតពិនិត្យការបំពុលបរិស្ថាន និង /ឬ ការប្រើប្រាស់ថាមពលអគ្គិសនី និង /ឬ ឧបករណ៍បម្លែងសារធាតុគីមី) | បាទ<br>ទេ | ☐<br>☐ |
| | | | តើអាជ្ញាធរបានដាក់ចេញនូវបទបញ្ញាដើម្បីត្រួតពិនិត្យការបំពុលបរិស្ថានបង្កឡើងដោយចរាចរណ៍ឬទេ? (ដូចជាការហាមឃាត់រថយន្តដែលបញ្ចេញ សារធាតុពុលច្រើន ការផាកពិន័យលើការកកស្ទះចរាចរណ៍ ក្នុងទីក្រុង...) | បង្ហាញភស្តុតាងដែលនៅបន្តមាននៃបទបញ្ញាជាក់ស្ដែង និងវិធានការ ដើម្បីត្រួតពិនិត្យការបំពុលបរិស្ថានបង្កឡើងពីចរាចរ | បាទ<br>ទេ | ☐<br>☐ |
| | | | តើទាំងនេះត្រូវបានអនុវត្តក្នុងទី | ផ្ដល់ភស្តុតាងនៃការអនុវត្តន៍នៃវិធានការ ដើម្បី | បាទ | ☐ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | ក្រុង ឬទេ? | បន្ធូរស្រោល និងត្រួតពិនិត្យការបំពុលបរិស្ថានបង្កឡើងពីចរាចរ (ដោយមានវត្តមាននៃអាជ្ញាធរទទួលខុសត្រូវ) ដូចជាការបម្រាមយានយន្តដែលបញ្ចេញឧស្ម័នខ្លាំង ការរៀបចំតំបន់បង់ថ្លៃពេលកកស្ទះ ក្នុងទីក្រុង។ល។ | ទេ | ☐ |
| | | | តើមានសមាមាត្រនៃការប្រើប្រាស់យានយន្តដែលគិតគូរដល់បរិស្ថាន និងយានជំនិះមិនប្រើប្រេងឥន្ធនៈធៀបទៅនឹងចំនួនយានជំនិះទាំងអស់ដែលមានប៉ុន្មានភាគរយ? | ផ្តល់ចំណាត់ថ្នាក់នៃប្រភេទយានដែលប្រើប្រាស់ដោយប្រជាជន ដោយចង្អុលបង្ហាញអំពីចំនួន និងសមាមាត្រនៃការប្រើប្រាស់យានដែលរក្សាបរិស្ថាន និងយានមិនប្រើម៉ាស៊ីន | ________ % (តិចបំផុត ៣០% នៃចំនួនសរុប ដើម្បីទទួលបាន ១ ពិន្ទុ) | |
| | | | តើអាជ្ញាធរបានលើកទឹកចិត្តប្រជាជន(ក្នុងស្រុក) ឲ្យប្រើប្រាស់មធ្យោបាយដឹកជញ្ជូនមិនប្រើឥន្ធនៈ ការជិះកង់ ឬ ការដើរដែរ ឬទេ? | បង្ហាញភស្តុតាងដែលនៅបន្តមាននៃវិធានការដែលលើកទឹកចិត្តឲ្យប្រជាពលរដ្ឋប្រើប្រាស់ការដឹកជញ្ជូនមិនប្រើម៉ាស៊ីន ដូចជា ការជិះកង់ និង ថ្មើជើង ។ល។ | បាទ<br>ទេ | ☐<br>☐ |
| ៥ | **ការប្រើប្រាស់ថាមពលប្រកបយនិរន្តរភាព** | តើផ្នែកទេសចរណ៍ឯកជនបានអនុវត្តវិធានការជាក់លាក់ និង/ឬយុទ្ធសាស្ត្រដើម្បីលើកទឹកចិត្តឲ្យប្រើប្រាស់ថាមពលប្រកបដោយនិរន្តរភាព? | តើមានសមមាត្រសណ្ឋាគារក្នុងទីក្រុងដែលប្រើប្រាស់ឧបករណ៍សន្សំសំចៃអគ្គិសនី និងថាមពលកកើតឡើងវិញ? | ផ្តល់ទិន្នន័យឧស្សាហកម្មទេសចរណ៍ជាមួយចំណាត់ថ្នាក់សណ្ឋាគារដែលប្រើប្រាស់ថាមពលប្រកបដោយសន្សំសំចៃ និងឧបករណ៍/បច្ចេកវិជ្ជាប្រកបដោយសមត្ថភាព(ដូចជា អំពូលភ្លើងអេកូ កុងតាក់បើក-បិទ ការប្រើប្រាស់សោរកាត...)<br>វិធានការអនុវត្តរបស់សណ្ឋាគារដើម្បីលើកទឹកចិត្តដល់ភ្ញៀវឲ្យសន្សំសំចៃថាមពល គឺជាការចាំបាច់ផងដែរ | តិចជាង៥០%<br>រហូតដល់ ឬច្រើនជាង ៥០%<br>(តិចបំផុត៥០% ដើម្បីទទួលបាន១ពិន្ទុ) | ☐<br>☐ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | តើមានសមាមាត្រនៃភោជនីយ-ដ្ឋានក្នុងទីក្រុងដែលប្រើប្រាស់ឧបករណ៍សន្សំសំចៃអគ្គិសនី និងថាមពលកកើតឡើងវិញប៉ុន្មានភាគរយ ? | ផ្តល់ទិន្នន័យឧស្សាហកម្មទេសចរណ៍ជាមួយ ចំណាត់ថ្នាក់ភោជនីយដ្ឋានដែលប្រើប្រាស់ថាមពលប្រកបដោយសន្សំសំចៃ និងឧបករណ៍/បច្ចេកវិជ្ជាប្រកបដោយសមត្ថភាព (ដូចជាដាក់ ភ្លើងបំភ្លឺ ផ្គត់ផ្គង់ទឹកក្តៅខ្យល់អាកាស ផ្ទះបាយ ម៉ាស៊ីនកំដៅ ម៉ាស៊ីនត្រជាក់ ការថែទាំ និង/ឬ ថាមពលកើតឡើងវិញ(ថាមពលពន្លឺព្រះអាទិត្យ។ល។) | តិចជាង ៥0%<br><br>រហូត ដល់<br>ឬច្រើនជាង ៥0%<br>(តិចបំផុត៥0% ដើម្បីទទួលបាន១ពិន្ទុ) | ☐<br><br>☐ |
| | | | តើអាជីវកម្មទេសចរណ៍បានជ្រួតជ្រាប និងអាចប្រើប្រាស់បច្ចេកទេសសន្សំសំចៃថាមពលតាមរយៈយុទ្ធនាការផ្សព្វផ្សាយការយល់ដឹងនេះ ឬទេប៉ុន្មានភាគរយ? | ផ្តល់វត្តមាននៃវិធានការរួមទាំងយុទ្ធនាការបង្កើតការយល់ដឹងអំពីបច្ចេកទេសសន្សំសំចៃថាមពល និងដើមគំនិតប្រើប្រាស់ថាមពលប្រកបដោយសមត្ថភាព សំដៅចំពោះអាជីវកម្មទេសចរណ៍ក្នុង ទីក្រុង | បាទ<br>ទេ | ☐<br>☐ |
| | | | តើមានវិធានការលើកទឹកចិត្តសម្រាប់ការប្រើប្រាស់ថាមពលប្រកបដោយនិរន្តភាពឬទេ? | ផ្តល់បញ្ជីនៃវិធានការផ្តល់គ្រឿងលើកទឹកចិត្ត ដើម្បី លើកទឹកចិត្តដល់ការប្រើប្រាស់ថាមពលប្រកបដោយនិរន្តរភាព (ភាពញឹកញាប់ប្រភេទសកម្មភាព...) និងលទ្ធផល (តាមដានរបៀបប្រើប្រាស់ថាមពលប្រកបដោយសមត្ថភាព ការថយចុះនៃបរិមាណប្រើប្រាស់ថាមពល។ល។) | បាទ<br>ទេ | ☐<br>☐ |
| - **ចំនួននៃសូចនករលំអិត៖ ៥**<br>- **ចំនួននៃលក្ខណៈវិនិច្ឆ័យ៖ ២៨** | | | | | **សរុប** | **២៨** |

## ២)-តារាងវាយតម្លៃលើសូចនាករចំនួន០៤ នៃភាពស្អាត

| ភាពស្អាត | | គម្រូចការសម្រាប់ លក្ខណៈវិនិច្ឆ័យសំខាន់ៗ | លក្ខណៈវិនិច្ឆ័យ | ភស្តុតាងសម្រាប់ លក្ខណៈវិនិច្ឆ័យ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|---|---|---|
| ១ | **ភាពស្អាតនៅតាមទីកន្លែងសាធារណៈ** | តើទីក្រុងបានវាយតម្លៃ និងថែទាំជាប្រចាំលើភាពស្អាតបាននៃទីសាធារណៈ ឬទេ? | តើអាជ្ញាធរក្រុងបានធ្វើការសម្អាតទីសាធារណៈញឹកញាប់កម្រិតណា? | ផ្តល់ភស្តុតាងដែលថាក្រុងបានលាងសំអាតទីសាធារណៈជាប្រចាំ (ភាពនៅមាននៃអាជ្ញាធរទទួលបន្ទុកលើការថែទាំតារាងពេលនៃសកម្មភាពលាងសំអាត បេសកកម្ម បុគ្គលិកនិងឧបករណ៍) | ១ថ្ងៃម្តង ឬញឹកញាប់ជាង(តិចបំផុត១ថ្ងៃម្តងដើម្បីទទួលបាន១ពិន្ទុ)<br>តិចជាងម្តងក្នុង១ថ្ងៃ | ☐<br>☐ |
| | | | តើសំភារៈបរិក្ខារប្រើប្រាស់សាធារណៈ (បង់សាធារណៈ ចំណតឡានក្រុង។ល។) ត្រូវការថែទាំ និងសំអាតជាប្រចាំ ឬទេ? | ផ្តល់ភស្តុតាងដែលថាក្រុងបានលាងសំអាតគ្រឿងសង្ហារឹមសាធារណៈជាប្រចាំ(ភាពនៅមាននៃអាជ្ញាធរទទួលបន្ទុកលើការថែទាំតារាងពេលនៃសកម្មភាពលាងសំអាត បេសកកម្ម បុគ្គលិក និងឧបករណ៍) | បាទ<br>ទេ | ☐<br>☐ |
| | | | តើមានធុងសំរាមសាធារណៈគ្រប់គ្រាន់ទេនៅទីសាធារណៈ? | ផ្តល់ផែនទីនៃទីសាធារណៈចង្អុលបង្ហាញអំពីវត្តមាននៃធុងសំរាមសាធារណៈ និងបញ្ជាក់ច្បាស់អំពីចំនួនសរុបះតិចបំផុតគួរមានធុងសំរាមមួយនៅច្រកចូលនីមួយៗនៃអគារសាធារណៈ; ធុងសម្រាបពីរនៅកែងនីមួយៗ; ធុងសំរាមមួយក្នុង ២០០មែត្រនៅតាមបណ្តោយផ្លូវដើរនិងក្នុងឧទ្យាន។. | បាទ<br>ទេ | ☐<br>☐ |
| | | | តើសំរាមទាំងនេះត្រូវបានប្រមូល | ផ្តល់តារាងពេលលំអិតថាតើប៉ុន្មានដងក្នុងមួយ | បាទ | ☐<br>☐ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | សំរាមជាប្រចាំ ឬទេ? | ថ្ងៃដែលធុងសំរាមត្រូវបានយកចាក់ចោល | ទេ | |
| | | | តើអាគារសាធារណៈត្រូវបានដាក់ស្លាកសញ្ញាសមរម្យទេ? | ផ្តល់ផែនទីចង្អុលបង្ហាញអំពីអគារសាធារណៈ និងផ្លាកសញ្ញាចង្អុលបង្ហាញអំពីទីតាំងរបស់អគារ | បាទ<br>ទេ | ☐<br>☐ |
| ២ | **ភាពស្អាតនៅតាមបង្គន់សាធារណៈ** | តើទីក្រុងបានវាងតម្លៃ និងថែទាំភាពស្អាតបាតនៃបង្គន់សាធារណៈជាប្រចាំឬទេ? | តើបង្គន់សាធារណៈត្រូវបានសំអាត និងថែទាំជាប្រចាំឬទេ? (ភ្ជាប់ទៅនឹងស្តង់ដាបង្គន់សាធារណៈអាស៊ាន) | ផ្តល់ភស្តុតាងនៃភាពស្អាតបាតនិងការថែទាំនៃបង្គន់សាធារណៈ (ក្តារបិទប្រកាស, ស្លាប័នទទួលរ៉ាប់រង...)(យោងភ្ជាប់ទៅនិង**ស្តង់ដាបង្គន់សាធារណៈអាស៊ាន**) | បាទ<br>ទេ | ☐<br>☐ |
| | | | តើបង្គន់សាធារណៈត្រូវបានលាងសំអាតញឹកញាប់ប៉ុណ្ណា? | បង្ហាញភស្តុតាងវត្តមាននៃក្តារបិទប្រកាសដែលបិទប្រកាសអំពីតារាងពេលនៃការលាងសំអាត (ពេលវេលានៃការលាងសំអាតនាពេលខាងមុខ) និងបង្ហាញភស្តុតាងអំពីភាពញឹកញាប់និងគុណភាពនៃការថែទាំ | ២ដងក្នុងមួយថ្ងៃ ឬញឹកញាប់ ជាងនេះ (តិចបំផុត២ដងក្នុងមួយថ្ងៃដើម្បីទទួលបាន១ពិន្ទុ)<br>តិចជាង២ដងក្នុង១ថ្ងៃ | ☐<br>☐ |
| | | | តើមានបែងចែករវាងបង្គន់បុរស និងបង្គន់ស្រី និងបង្គន់សម្រាប់ជនពិការ ឬទេ? | ផ្តល់ផែនទីចង្អុលបង្ហាញអំពីបង្គន់សាធារណៈ និងភស្តុតាងនៃការដាក់ដាច់ដោយឡែកឲ្យបានសមរម្យរវាងបង្គន់ប្រុស បង្គន់ស្រីនិងបង្គន់អ្នកពិការ | បាទ<br>ទេ | ☐<br>☐ |
| | | | តើបង្គន់សាធារណៈត្រូវបានដាក់ស្លាកសញ្ញាត្រឹមត្រូវដែររ ឬទេ? | ផ្តល់ផែនទីចង្អុលបង្ហាញអំពីបង្គន់សាធារណៈ និងផ្លាកសញ្ញាបង្ហាញអំពីទីតាំងរបស់បង្គន់សាធារណៈ (រូបថត ជាភស្តុតាង) | បាទ<br>ទេ | ☐<br>☐ |

| | | | | | | |
|---|---|---|---|---|---|---|
| ៣ | **ភាពស្អាតនៅតាមរម្មណីដ្ឋានទេសចរណ៍** | តើក្រុងបានវាយតម្លៃ និងថែទាំភាពស្អាតបាតនៃទីកន្លែងទេសចរណ៍ ជាប្រចាំឬទេ? | តើតំបន់ទេសចរណ៍ត្រូវបានយកចិត្តទុកដាក់ជាពិសេសអំពីការសំអាតជាប្រចាំ ឬទេ? | បង្ហាញភស្តុតាងដែលថាក្រុងបានសំអាតតំបន់ទេសចរណ៍ជាប្រចាំ (ភាពនៅមាននៃអាជ្ញាធរទទួលបន្ទុកការថែទាំតារាងពេលនៃសកម្មភាពសំអាត បេសកកម្ម បុគ្គលិក និងឧបករណ៍) | បាទ<br>ទេ | ☐<br>☐ |
| | | | តើទីកន្លែងទេសចរណ៍ត្រូវបានសម្អាតញឹកញាប់កម្រិតណា? | បង្ហាញភស្តុតាងនៃវត្តមាននៃក្តារបិទប្រកាសអំពីតារាងពេលសំអាត (ពេលវេលានៃការសំអាតនាពេលខាងមុខ) និងបង្ហាញភស្តុតាងអំពីភាពញឹកញាប់ និងគុណភាពនៃការថែទាំ | ២ម្តងក្នុង១ថ្ងៃ ឬញឹកញាប់ជាងនេះ (តិចបំផុត២ម្តងក្នុងមួយថ្ងៃដើម្បីទទួលបាន១ពិន្ទុ)<br>តិចជាង២ដងក្នុង១ថ្ងៃ | ☐<br>☐ |
| | | | តើមានធុងសំរាមនៅទីកន្លែងទេសចរណ៍គ្រប់គ្រាន់ឬទេ? | ផ្តល់ផែនទីទីកន្លែងទេសចរណ៍ចង្អុលបង្ហាញអំពីវត្តមាននៃធុងសំរាមសាធារណៈនិងបញ្ជាក់ច្បាស់ចំនួនសរុបៈ តិចបំផុត មានធុងសំរាមមួយនៅច្រកចូលនីមួយៗធុងសម្រាមពីរនៅកែងនីមួយៗធុងសំរាមមួយក្នុង២០០មែត្រនៅតាមបណ្តោយផ្លូវដើរ និងឧទ្យាន។ | បាទ<br>ទេ | ☐<br>☐ |
| | | | តើមានបង្គន់នៅទីកន្លែងទេសចរណ៍គ្រប់គ្រាន់ឬទេ? | បង្ហាញភស្តុតាង យ៉ាងហោចណាស់ៈ មានបង្គន់មួយនៅទីកន្លែងទេសចរណ៍មួយផ្អែកលើភាពញឹកញាប់ សមត្ថភាព និងប្រភេទនៃទីកន្លែងទេសចរណ៍ (ឧទាហរណ៍ដូចជាមានបង្គន់មួយក្នុង៥០០ម៉ែត្រ ឬបង្គន់មួយក្នុងមនុស្ស៤០នាក់) | បាទ<br>ទេ | ☐<br>☐ |
| | | | តើទីកន្លែងទេសចរណ៍ត្រូវបានដា | ផ្តល់ផែនទីចង្អុលបង្ហាញអំពីទីកន្លែងទេចរណ៍ | បាទ | ☐<br>☐ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | ក់ស្លាកសញ្ញាសមរម្យឬទេ? | និងផ្លាកសញ្ញាបង្ហាញអំពីទីតាំងនៃកន្លែងទេសចរណ៍ (រូបថត ជាភស្តុតាង) | ទេ | |
| ៤ | **ភាពស្អាតនៅតាមបណ្តោយផ្លូវធំ** | តើក្រុងបានវាយតម្លៃ និងថែទាំភាពស្អាតបាត នៅតាមបណ្តោយផ្លូវធំ ឬទេ? | តើតំបន់ជុំវិញផ្លូវធំក្នុងទីក្រុងត្រូវបានសម្អាត ញឹកញាប់ឬទេ? | បង្ហាញភស្តុតាងដែលថាក្រុងបានសំអាតតំបន់ជុំវិញផ្លូវធំជាប្រចាំ (ភាពនៅមាននៃអាជ្ញាធរទទួលរ៉ាប់រងការថែទាំតារាងពេលនៃសកម្មភាពសំអាត បេសកកម្ម និងបុគ្គលិក) | ២ដងក្នុង១ថ្ងៃ ឬញឹកញាប់ជាង (តិចបំផុត២ដងក្នុងមួយថ្ងៃដើម្បីទទួលបាន១ពិន្ទុ)<br>តិចជាង២ដងក្នុង១ថ្ងៃ | ☐<br>☐ |
| | | | តើឧបករណ៍ត្រូវបានប្រើប្រាស់សមរម្យឬទេ? (ចន្លោះពីធុងសំរាមមួយទៅមួយត្រូវបំពាក់ឲ្យបានស្មើៗគ្នា) | ផ្តល់បញ្ជីនៃឧបករណ៍ និងស្ថានភាពឧបករណ៍ដែលត្រូវបានប្រើសម្រាប់គោលបំណងលាងសំអាត | បាទ<br>ទេ | ☐<br>☐ |
| - **ចំនួននៃសូចនករលំអិត៖ ៤**<br>- **ចំនួននៃលក្ខណៈវិនិច្ឆ័យ៖ ១៦** | | | | | **សរុប** | **១៦** |

**៣)-តារាងវាយតម្លៃលើសូចនាករចំនួន០៥ នៃការគ្រប់គ្រងសំណល់**

| **ការគ្រប់គ្រងកាកសំណល់** | | **តម្រូវការសម្រាប់លក្ខណៈវិនិច្ឆ័យសំខាន់ៗ** | **លក្ខណៈវិនិច្ឆ័យ** | **ភស្តុតាងសម្រាប់លក្ខណៈវិនិច្ឆ័យ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|---|---|---|---|
| ១ | **ការប្រមូលសំណល់រាវ** | គុណភាពនៃការប្រមូលកាកសំណល់រាវ | តើមានប្រពន្ធ័ប្រមូលកាកសំណល់រាវក្នុងទីក្រុងឬទេ? | ផ្តល់ផែនទីនៃភាពនៅមាននៃប្រព័ន្ធប្រមូលកាកសំណល់រាវ | បាទ<br>ទេ | ☐<br>☐ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | តើមានបទដ្ឋានពាក់ព័ន្ធ នឹងការប្រមូលកាកសំណល់រាវឬទេ? | ផ្តល់បទដ្ឋាននៃភាពនៅមានដែលពាក់ព័ន្ធនិងការប្រមូលកាកសំណល់រាវ | បាទ<br>ទេ | ☐<br>☐ |
| | | | តើមានការដាក់ចេញនូវវិធានការដើម្បីដាក់ទោសការបំពានលើបទដ្ឋាននេះឬទេ? | ផ្តល់បញ្ជីនៃវិធានការដាក់ចេញដោយអាជ្ញាធរពាក់ព័ន្ធដើម្បីត្រួតពិនិត្យបទដ្ឋាននេះ (ដោយដាក់ ទោសដល់ការបំពានលើបទដ្ឋាននេះ) | បាទ<br>ទេ | ☐<br>☐ |
| | | | ភាគរយនៃចំនួនប្រជាជនទីក្រុងដែលបានភ្ជាប់ទៅនឹងប្រព័ន្ធលូ? | ផ្តល់ :<br>-ផែនទីនៃតំបន់ដែលភ្ជាប់ទៅនិងប្រព័ន្ធមេលូ បង្ហូរ ទឹកដោយមានការគ្របផ្ទៃលើ<br>-ភាគរយនៃចំនួនប្រជាជនទីក្រុងដែលបានភ្ជាប់ទៅនិងប្រព័ន្ធ | ............%(តិចបំផុត ៧០%នៃ ចំនួនសរុបដើម្បីទទួលបាន១ពិន្ទុ) | ☐ |
| | | | តើសម្បទាទេសចរណ៍ដែលបានភ្ជាប់ទៅនឹងលូមេបង្ហូរទឹកមានប៉ុន្មានភាគរយ? | ផ្តល់ផែនទីចង្អុលបង្ហាញអំពីសម្បទាទេសចរណ៍ដែលត្រូវបានភ្ជាប់ទៅនិងប្រព័ន្ធមេលូបង្ហូរទឹក និងភាគរយនៃសម្បទាដែលបានភ្ជាប់ | .........%(តិចបំផុត៧០%នៃ ចំនួនសរុបដើម្បីទទួលបាន១ពិន្ទុ) | ☐ |
| | | | តើមានមធ្យោបាយបន្ថែមណាដែលបានប្រើដើម្បីបញ្ចេញកាកសំណល់រាវ? | -បង្ហាញភស្តុតាងដែលនៅបន្តមាននៃមធ្យោបាយ បន្ថែមដែលបានប្រើដើម្បីយកកាកសំណល់រាវចាក់ចោល<br>-ផ្តល់ឈ្មោះនៃអាជ្ញាធរ / ស្ថប័នទទួលបន្ទុក<br>-ផ្តល់ភាពញឹកញាប់នៃការប្រមូលនិងការគ្រប គម្របផ្ទៃលើ ឬតំបន់ | អាងផ្ទុកទឹកសំអុយរួម<br>អាងផ្ទុកទឹកសំអុយឯកជនអណ្តូងស្ងួត (ត្រាំចោលឆ្ងាយ)<br>គ្មានប្រព័ន្ធចាត់ចែងបង្ហូរចោល (គ្មានពិន្ទុ) | ☐<br>☐<br>☐<br>☐ |

| | | | | | | |
|---|---|---|---|---|---|---|
| ២ | **ការប្រមូលសំណល់រឹង** | គុណភាពនៃការប្រមូលកាកសំណល់រឹង | តើក្រុងបានប្រមូលកាកសំណល់រឹងឬទេ? | បើក្រុងប្រមូលកាកសំណល់រឹងបង្ហាញភស្តុតាងៈ<br>-អាជ្ញាធរ/ស្ថាប័នទទួលបន្ទុកលើការប្រមូល<br>-ភាពញឹកញាប់នៃការប្រមូល<br>-គ្របផ្ទៃលើ/តំបន់ ក្នុងទីក្រុង | បាទ<br>ទេ | ☐<br>☐ |
| | | | បើគ្មាន តើកាកសំណល់រឹងត្រូវប្រមូលដោយរបៀបណា? | ផ្តល់កិច្ចសន្យាដែលចុះហត្ថលេខាជាមួយក្រុមហ៊ុនឯកជន ឬ ដៃគូដទៃដើម្បីប្រមូលចោលកាកសំណល់រឹង និងសុពលភាពនៃកិច្ចសន្យា | ក្រុមហ៊ុនឯកជន<br>អង្គការ NGO (បញ្ជាក់ឲ្យច្បាស់) | ☐<br>☐ |
| | | | តើកាកសំណល់រឹងត្រូវបានប្រមូលចោលញឹកញាប់ឬទេ? | ផ្តល់ៈ<br>-អាជ្ញាធរទទួលបន្ទុកនៃការប្រមូលចោលកាកសំណល់រឹង<br>-តារាងពេលនៃការ ប្រមូល កាកសំណល់រឹង បុគ្គលិក និងឧបករណ៏ | មួយថ្ងៃម្តង ឬច្រើនជាងនេះ (តិចបំផុត១ថ្ងៃម្តងដើម្បីទទួលបាន១ពិន្ទុ)<br>តិចជាង១ដងក្នុង១ថ្ងៃ | ☐<br>☐ |
| | | | តើសមាមាត្រប្រជាជនដែលបានភ្ជាប់ទៅនឹងប្រព័ន្ធចាត់ចែងប្រមូលកាកសំណល់រឹងមានប៉ុន្មានភាគរយ? | ផ្តល់ :<br>-ផែនទីនៃតំបន់ដែលភ្ជាប់ទៅនិងប្រព័ន្ធដោយចង្អុលបង្ហាញអំពីការគ្របគម្របផ្ទៃលើ<br>-ភាគរយនៃចំនួនប្រជាជនទីក្រុងដែលបានភ្ជាប់ ទៅនិងប្រព័ន្ធ | ...........%(តិចបំផុត ៧០%នៃចំនួនសរុបដើម្បីទទួលបាន១ពិន្ទុ | ☐ |
| | | | តើសម្បទាទេសចរណ៏ដែលបានភ្ជាប់ទៅនឹងប្រព័ន្ធប្រមូលកាក | ផ្តល់ផែនទីចង្អុលបង្ហាញអំពីសម្បទាទេសចរ | ...........%(តិចបំផុត ៧០%នៃចំនួនសរុប | ☐ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | សំណល់មានប៉ុន្មានភាគរយ? | ណ៍ដែលបានភ្ជាប់ទៅនិងប្រព័ន្ធនិងភាគរយនៃ សម្បទាដែលបានភ្ជាប់ | ដើម្បីទទួលបាន១ពិន្ទុ | |
| ៣ | **ការរក្សាទុកសំណល់រាវ និងការធ្វើប្រព្រឹត្តិកម្ម** | គុណភាពនៃការរក្សាទុកកាកសំណល់រាវ និងការធ្វើប្រព្រឹត្តិកម្ម | តើមានតំបន់រក្សាទុកកាកសំណល់រាវដែលប្រជាពលរដ្ឋទីក្រុងអាចប្រើប្រាស់បានឬទេ? | ផ្តល់ផែនទីចង្អុលបង្ហាញតំបន់រក្សាទុកកាកសំណល់រាវក្នុងទីក្រុង | បាទ<br>ទេ | ☐<br>☐ |
| | | | តើមានសម្បទាសម្រាប់រក្សាទុកសំណល់(ដូចជាអាងចម្រោះទឹកសំអុយ) នៅជិតតំបន់ទេស ចរណ៍ដែរឬទេ? | លំអិតអំពីទីតាំង និងចំនួនសម្បទាសម្រាប់រក្សា ទុក (ដូចជា អាងផ្ទុកទឹកសំអុយ)នៅជិតតំបន់ ទេសចរណ៍និងតារាងពេលនៃការប្រមូលចោល | បាទ<br>ទេ | ☐<br>☐ |
| | | | តើមានរោងចក្រធ្វើប្រព្រឹត្តិកម្មនៅជិតទីក្រុងឬទេ? | ផ្តល់ផែនទីនៃរោងចក្រធ្វើប្រព្រឹត្តិកម្មទឹកសំអុយ បើមាន នៅជិតទីក្រុង និងបញ្ជាក់ឲ្យបានច្បាស់ អំពីលក្ខណៈបច្ចេកទេស សមត្ថភាព...) | បាទ<br>ទេ | ☐<br>☐ |
| ៤ | **ការរក្សាទុកសំណល់រឹង និងការធ្វើប្រព្រឹត្តិកម្ម** | គុណភាពនៃការរក្សាទុកកាកសំណល់រឹង និងការធ្វើប្រព្រឹត្តិកម្ម | តើមានតំបន់សម្រាប់ចាក់កាកសំណល់ចោលឋ (ដូចជា កន្លែងចាក់សំរាមរោងចក្រដុតរំលាយ) នៅជិតទីក្រុងឬទេ? | ផ្តល់ផែនទីនៃតំបន់សម្រាប់ចាក់ចោលកាកសំណល់រឹងនៅជិតទីក្រុងនិងបញ្ជាក់ឲ្យបានច្បាស់អំពីលក្ខណៈបច្ចេកទេស (សមត្ថភាព...) | បាទ<br>ទេ | ☐<br>☐ |
| | | | តើមានរោងចក្រធ្វើប្រព្រឹត្តិកម្មនៅជិតក្រុងឬទេ? | ផ្តល់ផែនទីនៃការធ្វើប្រព្រឹត្តិកម្មកាកសំណល់រឹងនិងរោងចក្របម្លែងប្រើឡើងវិញ នៅជិតទីក្រុង និងបញ្ជាក់ឲ្យបានច្បាស់អំពីលក្ខណៈបច្ចេកទេស (ប្រភេទសមត្ថភាព ទំហំនៃកាកសំណល់ដែល ប្រមូល និងធ្វើប្រព្រឹត្តិកម្ម...) | បាទ<br>ទេ | ☐<br>☐ |

| | | | | | | |
|---|---|---|---|---|---|---|
| ៥ | **ការប្រើប្រាស់ឡើងវិញ** | តើមានយុទ្ធសាស្ត្រ និងវិធានការដើម្បីផ្សព្វផ្សាយការប្រើប្រាស់ឡើងវិញ ឬទេ? | តើអាជ្ញាធរក្រុងបានលើកទឹកចិត្តដល់ការប្រើប្រាស់ឡើងវិញ និងប្រមូលកាកសំណល់ពីកន្លែងប្រជាជនឬទេ? | បង្ហាញភស្តុតាងភាពនៅមាននៃវិធានការលើក ទឹកចិត្តដល់ការប្រើប្រាស់ឡើងវិញ និងប្រមូលកាកសំណល់ដែលប្រើឡើងវិញបាន | បាទ<br>ទេ | ☐<br>☐ |
| | | | តើមានប្រព័ន្ធប្រមូលកាកសំណល់ពុល និងកាកសំណល់ប៉ះពាល់បរិស្ថាន ឬទេ? | បង្ហាញភស្តុតាងភាពនៅមាននៃប្រព័ន្ធប្រមូលកាកសំណល់ពុលនិងកាកសំណល់ប៉ះពាល់បរិស្ថាន (ឃ្លាំង តារាងពេលនៃការប្រមូល សមត្ថភាព...) | បាទ<br>ទេ | ☐<br>☐ |
| | | | តើមានឧបករណ៍សមរម្យសម្រាប់ធ្វើការកែច្នៃ ឬទេ? (ដូចជាធុងដែលមានការអប់រំបែងចែកសំរាមបីប្រភេទជាដើម) | លំអិតអំពីចំនួនទីតាំងនិងប្រភេទនៃធុងសំរាមដែលចង្អុលបង្ហាញអំពីគោលបំណងនៃការប្រើប្រាស់ឡើងវិញ | បាទ<br>ទេ | ☐<br>☐ |
| | | | តើមានការធ្វើយុទ្ធនាការផ្សព្វផ្សាយបញ្ជ្រាបយល់ដឹងជាប្រចាំឬទេអំពីការប្រើប្រាស់ឡើងវិញសម្រាប់ប្រជាជន និងសហគ្រាសក្នុងវិស័យទេសចរណ៍? | បង្ហាញភស្តុតាងភាពនៅមាននៃយុទ្ធនាការផ្សព្វផ្សាយការយល់ដឹង (ប្រភេទនៃយុទ្ធនាការ ប្រដាប់ប្រដា/មធ្យោបាយ ចំពោះអ្នកណា និង ភាពញឹកញាប់) | បាទ<br>ទេ | ☐<br>☐ |
| - **ចំនួននៃសូចនករលំអិត៖ ៥**<br>- **ចំនួននៃលក្ខណៈវិនិច្ឆ័យ៖ ២០** | | | | | **សរុប** | **២០** |

## ៤)-តារាងនៃការវាយតម្លៃលើសូចនករចំនួន៣ នៃការបង្កើតការយល់ដឹងអំពីកិច្ចការពារបរិស្ថាន និងសូចនករនៃភាពស្អាត

| ការបង្កើនការយល់ដឹងអំពីកិច្ចការពារបរិស្ថាន និងសូចនករនៃភាពស្អាត | | តម្រូវការសម្រាប់លក្ខណៈវិនិច្ឆ័យសំខាន់ៗ | លក្ខណៈវិនិច្ឆ័យ | ភស្តុតាងសម្រាប់លក្ខណៈវិនិច្ឆ័យ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|---|---|---|
| ១ | **ការបញ្ជ្រាបការយល់ដឹងដល់ប្រជាជនក្នុងស្រុកអំពីការការពារបរិស្ថាន និងភាពស្អាត** | តើមានសកម្មភាព ឬយុទ្ធសាស្ត្រដើម្បីបង្កើនការយល់ដឹងដល់ប្រជាជនក្នុងស្រុកអំពីការការពារបរិស្ថាន និងភាពស្អាតបាត ឬទេ? | តើមានយុទ្ធនាការការបញ្ជ្រាបការយល់ដឹង (ផ្សព្វផ្សាយសធារណៈ ព្រឹត្តិការណ៍ផ្សេងៗ កម្មវិធីប្រកួតប្រជែងនានា...)ដល់ប្រជាជនក្នុងស្រុក ស្តីអំពីកិច្ចការពារបរិស្ថាន និងភាពស្អាត ឬទេ? | បង្ហាញភស្តុតាងដែលនៅបន្តមាននៃយុទ្ធនាការបង្កើនការយល់ដឹងដោយបង្ហាញភស្តុតាងអំពីប្រភេទនៃយុទ្ធនាការ និងចំពោះក្រុមណានៃប្រជាជនក្នុងស្រុក | បាទ<br>ទេ | ☐<br>☐ |
| | | | តើញឹកញាប់កម្រិតណា? | បង្ហាញភស្តុតាងអំពីភាពញឹកញាប់ | ___ពេល(តិចបំផុតមួយឆ្នាំម្តងដើម្បីទទួលបាន១ពិន្ទុ) | |
| | | | តើអាជ្ញាធរបានផលិត និងចែកចាយឯកសារផ្សព្វផ្សាយសាធារណៈស្តីអំពីកិច្ចការពារបរិស្ថាន និងភាពស្អាត(កូនសៀវភៅ, ប័ណ្ណផ្ទត់ បដា ប័ណ្ណប្រកាស ឬទេ | បង្ហាញភស្តុតាងនៃឯកសារផ្សព្វផ្សាយដែលប្រើសម្រាប់យុទ្ធនាការបង្កើនការយល់ដឹងដោយផ្តល់នូវគំរូនៃឯកសារនីមួយៗ (សៀវភៅប័ណ្ណផ្ទត់ បដា និងប័ណ្ណផ្សព្វផ្សាយ...) | បាទ<br>ទេ | ☐<br>☐ |

| | | | | | | |
|---|---|---|---|---|---|---|
| ២ | **ការបញ្ជ្រាបការយល់ដឹងដល់ក្រុមហ៊ុនទេសចរណ៍អំពីបរិស្ថាន និងភាពស្អាត** | តើមានសកម្មភាព ឬ យុទ្ធសាស្ត្រដើម្បីបង្កើនការយល់ដឹងដល់ក្រុហ៊ុនទេសចរណ៍ស្តីពីការការពារបរិស្ថាន និងភាពស្អាតបាត ឬទេ? | តើមានយុទ្ធការបញ្ជ្រាបការយល់ដឹង(ផ្សព្វផ្សាយជាសាធារណៈ ព្រឹត្តិការណ៍ប្រកួតប្រជែងដល់បុគ្គលិកនៃសហគ្រាសទេសចរណ៍ស្តីអំពីការការពារបរិស្ថាននិងភាពស្អាត ឬទេ? | បង្ហាញភស្តុតាងដែលនៅបន្តមាននៃយុទ្ធនាការបង្កើនការយល់ដឹងដោយបញ្ជាក់អំពីប្រភេទនៃយុទ្ធនាការ និងសម្រាប់ក្រុមហ៊ុនទេសចរណ៍ ណាខ្លះ | បាទ<br>ទេ | ☐<br>☐ |
| | | | តើញឹកញាប់កម្រិតណា? | បង្ហាញភស្តុតាងអំពីភាពញឹកញាប់ | ___ពេល(តិចបំផុតមួយឆ្នាំម្តងដើម្បីទទួលបាន១ពិន្ទុ) | |
| | | | តើមានឧបករណ៍ និងសកម្មភាពសមរម្យសម្រាប់គោលបំណងនេះ ឬទេ? | ផ្តល់បញ្ជី និងគំរូ នៃប្រដាប់ប្រដា និងបញ្ជីសកម្មភាពដែលបានប្រើសម្រាប់គោលបំណងយុទ្ធនាការ | បាទ<br>ទេ | ☐<br>☐ |
| ៣ | **ការបញ្ជ្រាបការយល់ដឹងដល់ទេសចរអំពីកិច្ចការពារបរិស្ថាន និងភាពស្អាត** | តើមានសកម្មភាព ឬ យុទ្ធសាស្ត្រដើម្បីបង្កើនការយល់ដឹងដល់ទេសចរអំពីការការពារបរិស្ថាន និងភាពស្អាត ឬទេ? | តើទេសចរបានយល់ដឹងអំពីកិច្ចខិតខំរបស់អាជ្ញាធរក្រុងលើកិច្ចការពារបរិស្ថាននិងភាពស្អាត និងបទបញ្ញត្តិ ឬទេ? | បង្ហាញភស្តុតាងនៃភាពនៅមាននៃយុទ្ធនាការបង្កើនការយល់ដឹងដោយបញ្ជាក់អំពីប្រភេទនៃយុទ្ធនាការ និងសម្រាប់ក្រុមទេសចរណាខ្លះ? | បាទ<br>ទេ | ☐<br>☐ |
| | | | តើញឹកញាប់កម្រិតណា? | បង្ហាញភស្តុតាងអំពីភាពញឹកញាប់ | ___ពេល(តិចបំផុតមួយឆ្នាំម្តងដើម្បីទទួលបាន១ពិន្ទុ | |
| | | | តើមានសម្ភារៈ និងសកម្មភាពសមរម្យឬទេសម្រាប់គោលបំណងនេះ ឬទេ? | បញ្ជាក់ភស្តុតាងថា សម្ភារៈនិងសកម្មភាពដែលបានអនុវត្ត ត្រូវទទួលយកបាន និងយល់ជ្រាប | បាទ<br>ទេ | ☐<br>☐ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | ដោយទេសចរ (ភាពនៅមានបន្តនៃសៀវភៅ បដា និងប័ណ្ណផ្សព្វផ្សាយ ជាភាសារអង់គ្លេស ទីតាំង (នៅតំបន់ងាយរងគ្រោះ ឧទ្យាន មាត់ទន្លេ នៅព្រៃ...) | | |
| - **ចំនួននៃសូចនករលំអិត៖ ៣**<br>- **ចំនួននៃលក្ខណៈវិនិច្ឆ័យ៖ ៩** | | | | | **សរុប** | **៩** |

## ៥)-តារាងវាយតម្លៃលើសូចនករចំនួន២ នៃតំបន់បៃតង

| **ទីធ្លាបៃតង** | | **តម្រូវការសម្រាប់លក្ខណៈវិនិច្ឆ័យសំខាន់ៗ** | **លក្ខណៈវិនិច្ឆ័យ** | **ភស្តុតាងសម្រាប់លក្ខណៈវិនិច្ឆ័យ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|---|---|---|---|
| ១ | **ទំហំតំបន់បៃតងក្នុងទីក្រុង** | តំបន់ទីវាល ក្នុងទីក្រុង ត្រូវបានលៃលកទុកសម្រាប់ធ្វើជាទីធ្លាបៃតង | តើមានសួនច្បារប៉ុន្មានក្នុងទីក្រុង? | ផ្តល់៖<br>-ផែនទីចង្អុលបង្ហាញអំពីឧទ្យានក្នុងទីក្រុង និងចំនួនសរុប<br>-គម្រោងអភិវឌ្ឍឧទ្យានកំពុងដំណើការ (តារាងពេល...) | ___(ចំនួន) (តិចបំផុតមួយឆ្នាំម្តងដើម្បីទទួលបាន១ពិន្ទុ) | |
| | | | តើសមាមាត្រនៃតំបន់បៃតងមានប៉ុន្មានភាគរយធៀបទៅនឹងផ្ទៃដីសរុបដែលមានក្នុងទីក្រុង? | បញ្ជាក់ភស្តុតាងជាភាគរយនៃចំនួនទីធ្លាបៃតងធៀបទៅនិងតំបន់ទីវាលទាំងអស់ដែលមានក្នុង | ___%(តិចបំផុតមួយ ៥%ដើម្បីទទួលបាន១ពិន្ទុ) | |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | ទីក្រុង | | |
| | | តើមានវិធានការ ដើម្បី គ្រប់គ្រង និងថែទាំទីធ្លា បៃតង ក្នុងទីក្រុង ឲ្យបាន សមរម្យ ឬទេ? | តើស្ថាប័នណាមួយដែលទទួលបន្ទុកថែទាំ និងគ្រប់គ្រងតំបន់បៃតង? | ផ្តល់៖<br>-ឈ្មោះនៃអាជ្ញាធរទទួលបន្ទុក (ជាមួយសេចក្តីសម្រេចរបស់ក្រុង) និង/ឬ កិច្ចសន្យាជាមួយក្រុមហ៊ុនស្តីពីការថែទាំ<br>-បញ្ជីការងារ<br>-ក្តារបិទប្រកាស | អាជ្ញាធរសាធារណៈ<br>ក្រុមហ៊ុនឯកជនផ្សេងៗ (ដូចជាNGO) (បញ្ជាក់ឲ្យច្បាស់) បើ<br>គ្មាន(គ្មានពិន្ទុ) | ☐<br>☐<br>☐ |
| ២ | **ការថែទាំ និងគ្រប់គ្រង តំបន់បៃតង** | | តើមានការថែទាំ និងកម្មវិធីគ្រប់គ្រងជាប្រចាំតាមតារាងពេលវេលាឬទេ? | ផ្តល់តារាងពេលប្រចាំខែដើម្បីបញ្ជាក់ភស្តុតាងអំពីភាពញឹកញាប់នៃការថែ និងគ្រប់គ្រង | បាទ<br>ទេ | ☐<br>☐ |
| | | | តើមានប្រព័ន្ធគ្រប់គ្រងបរិស្ថានកំពុងដំណើរការឬទេ? (ប្រព័ន្ធសន្សំសំចៃថាមពលសម្រាប់ការបំភ្លឺជាដើម ប្រព័ន្ធធារាសាស្ត្រ ការប្រើប្រាស់ជីសរីរាង្គ) | ផ្តល់៖<br>-លំអិតនៃប្រព័ន្ធបំភ្លឺ<br>-ជម្រើសនៃចំពូកក្រុម<br>-ការប្រើប្រាស់សមហេតុផលនៃធនធានធម្មជាតិ (តារាងពេលស្រោចទឹក)<br>-បរិមាណនៃជីសរីរាង្គដែលប្រើប្រាស់សម្រាប់ឧទ្យាន | បាទ<br>ទេ | ☐<br>☐ |
| - **ចំនួននៃសូចនករលំអិត៖ ២**<br>- **ចំនួននៃលក្ខណៈវិនិច្ឆ័យ៖ ៥** | | | | | **សរុប** | **៥** |

## ៦)-តារាងវាយតម្លៃលើសូចនករចំនួន៤ នៃសុវត្ថិភាពសុខភាព និង សន្តិសុខ និងសុវត្ថិភាពទីក្រុង

| សុវត្ថិភាពសុខភាព និង សន្តិសុខ និងសុវត្ថិភាព ទីក្រុង | | តម្រូវការសម្រាប់ លក្ខណៈវិនិច្ឆ័យសំខាន់ៗ | លក្ខណៈវិនិច្ឆ័យ | ភស្តុតាងសម្រាប់លក្ខណៈវិនិច្ឆ័យ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|---|---|---|
| ១ | **សុវត្ថិភាពសុខាភិបាល** | តើសុវត្ថិភាពសុខភាពត្រូវបានធានាក្នុងទីក្រុង? | តើមានមណ្ឌលសុខភាពគ្រប់គ្រាន់ក្នុងទីក្រុងដែរឬទេ? | ផ្តល់បញ្ជីលំអិត និងផែនទីនៃមណ្ឌលសុខភាពទាំងអស់ (បុគ្គលិក បរិក្ខា និងទំហំ..) ក្នុងទីក្រុង និងប្រៀបធៀបទៅនិងចំនួនប្រជាជនទាំងអស់ក្នុងទីក្រុង(យកទិន្នន័យនៃជម្រឿនប្រជាជនចុងក្រោយ) | មាន(តិចបំផុតមានមួយសម្រាប់អ្នកស្រុក៥០០នាក់ដើម្បីទទួលបាន ១ពិន្ទុ)<br>ទេ | ☐<br>☐ |
| | | | តើមានឱសថស្ថានក្នុងទីក្រុងគ្រប់គ្រាន់ដែរឬទេ? | ផ្តល់បញ្ជី និងផែនទីនៃឱសថស្ថានទាំងអស់ក្នុងទីក្រុង និងប្រៀធៀបទៅនិងចំនួនប្រជាជនទាំងអស់ក្នុងទីក្រុង (យកទិន្នន័យនៃជម្រឿនប្រជាជនចុងក្រោយ) | បាទ<br>(តិចបំផុតមានមួយសម្រាប់អ្នកស្រុក ៥០០នាក់ដើម្បីទទួលបានមួយពិន្ទុ)<br>ទេ | ☐<br>☐ |
| | | | តើមានបទដ្ឋានអនាម័យសម្រាប់កន្លែងដែល ទេសចរប្រមូលផ្តុំ ឬទេ? | ផ្តល់បទដ្ឋានអនាម័យជាក់ស្តែងបើមានសម្រាប់កន្លែងនីមួយៗដែលទេសចរប្រមូលផ្តុំគ្នា (ដូចជាភោជនីយដ្ឋាន ផ្សារ ហាងធ្វើនិងលក់ម្ហូបរហ័ស អ្នកលក់តាមផ្លូវ..) | បាទ<br>ទេ | ☐<br>☐ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | តើមានការធ្វើអធិការកិច្ចអំពីអនាម័យជាញឹកញាប់នៅកន្លែងដែលទេសចរប្រមូលផ្តុំ (ដូចជាៈ ភោជនីយដ្ឋាន ផ្សារ ហាងធ្វើ និងលក់ម្ហូបរហ័ស អ្នកលក់តាមផ្លូវ?) | ផ្តល់ឈ្មោះនៃអាជ្ញាធរទទួលបន្ទុកនៃការធ្វើអធិការកិច្ចតារាងពេលនៃការធ្វើអធិការកិច្ចអនាម័យនិងរបាយការណ៍ប្រចាំឆ្នាំដែលមានទាំងថ្ងៃខែនៃការធ្វើអធិការកិច្ចនីមួយៗ | រៀងរាល់ខែឬច្រើនជាងនេះ (តិចបំផុតមួយខែម្តងដើម្បីទទួលបាន១ពិន្ទុ)<br>តិចជាង១ដងក្នុង១ខែ យូរជាងមួយឆ្នាំ<br>មិនដែល | ☐<br>☐<br>☐ |
| ២ | **សុវត្ថិភាព និងសន្តិសុខទីក្រុង** | គុណភាពនៃសន្តិសុខ និងសុវត្ថិភាពក្នុងទីក្រុង | តើមានមន្ត្រីនគរបាលក្នុងទីក្រុងគ្រប់គ្រាន់ឬទេ?(ផ្អែកលើបទដ្ឋានប្រទេសរៀងខ្លួន) | ផ្តល់ចំនួនមន្ត្រីនគរបាលក្នុងទីក្រុង និងបទដ្ឋានប្រទេសពាក់ព័ន្ធនិងបញ្ហានេះ | បាទ<br>ទេ | ☐<br>☐ |
| | | | តើមានអង្គភាពនគរបាលទេសចរណ៍ក្នុងទីក្រុង ឬទេ? | ផ្តល់ៈ<br>-សេចក្តីសម្រេចរបស់រដ្ឋាភិបាលស្តីអំពីនគរបាលទេសរចណ៍ជាមួយតួនាទី និងការទទួលខុសត្រូវ<br>-ទីតាំងនៃអង្គភាពនគរបាលទេសចរណ៍ក្នុងទីក្រុង | បាទ<br>ទេ | ☐<br>☐ |
| | | | តើពួកគេត្រូវបានបណ្តុះបណ្តាលសមរម្យឬទេដើម្បីដោះស្រាយបញ្ហាដែលអាចកើតឡើងសម្រាប់ភ្ញៀវទេសចរ? | ផ្តល់ភាពល្អិតល្អន់អំពីការបណ្តុះបណ្តាលដែលរៀបចំឡើងមន្ត្រីនគរបាលទេសចរណ៍(ប្រភេទនៃវគ្គសម្ភារៈចំនួនអ្នកចូល រួម..) | បាទ<br>ទេ | ☐<br>☐ |
| ៣ | **ការទប់ស្កាត់បទឧក្រិដ្ឋ និងជម្រុញការអនុវត្តច្បាប់** | យុទ្ធសាស្ត្រ និង/ឬ វិធានការជាក់លាក់សម្រាប់បង្ការបទឧក្រិដ្ឋ | តើមានបទបញ្ញា វិធានការបង្ការ និងការពារនិងសកម្មភាពប្រឆាំងនឹងសកម្មភាពខុសច្បាប់ដែលប | បង្ហាញភស្តុតាងៈ<br>- ភាពនៅបន្តមាននៃច្បាប់ និងបទបញ្ញាពាក់ព័ន្ធ<br>- វិធានការបង្ការ និងការពារ និងសកម្មភាព | បាទ<br>ទេ | ☐<br>☐ |

| | | | | | | |
|---|---|---|---|---|---|---|
| | | និងការអនុវត្តច្បាប់ | ណ្តាលមកពីប្រតិបត្តិការក្នុងវិស័យទេសចរណ៍ ដើម្បីការពារប្រជាជនក្នុងស្រុក (ដូចជាៈ ពេស្យាចារកុមារ ថ្នាំញៀន ជួញដូរលួចលាក់វត្ថុខុសច្បាប់ ការខូចខាតដល់បរិស្ថាននិងសម្បត្តិវប្បធម៌..)? | ប្រតិបត្តិដោយអាជ្ញាធរ<br>- ទិន្នន័យចុងក្រោយនៃចំនួនបទឧក្រិដ្ឋពាក់ព័ន្ធទេសចរណ៍ នៅក្នុងទីក្រុង | | |
| | | | តើយុទ្ធនាការផ្សព្វផ្សាយការយល់ដឹងដើម្បីបញ្ចុះបញ្ចូលទេសចរមិនឲ្យប្រព្រឹត្តិអំពើខុសច្បាប់បានជាប្រចាំឬទេ? | បញ្ជាក់ភស្តុតាងដែលនៅបន្តមាននៃយុទ្ធនាការផ្សព្វផ្សាយការយល់ដឹង (ប្រភេទនៃយុទ្ធនាការចំពោះក្រុមទេសចរណាខ្លះ សម្ភារៈ/មធ្យោបាយ និងភាពញឹកញាប់) | បាទ<br>ទេ | ☐<br>☐ |
| ៤ | **យុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ** | យុទ្ធសាស្ត្រ និង/ឬ វិធានការដាក់លាក់សម្រាប់យុទ្ធសការគ្រប់ស្ត្រ (យកតាម ការអនុវត្តដ៏ប្រសើរបំផុតរបស់អាស៊ានស្តីពីសុវត្ថិភាព និងសន្តិសុខ) | តើបានរៀបចំឲ្យមានប្រព័ន្ធគ្រប់គ្រងហានិភ័យ ឬទេ? | ផ្តល់សេចក្តីសម្រេច និង/ឬឯកសារពាក់ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងវិបត្តិនៃទីក្រុង | បាទ<br>ទេ | ☐<br>☐ |
| | | | តើបានធ្វើបច្ចុប្បន្នភាពជាប្រចាំឬទេហើយអ្នកសំខាន់ៗបានចូលរួមបណ្តុះបណ្តាល និងជំនាញរបស់ពួកគេ ឬទេ? | ផ្តល់ៈ<br>- ទិន្នន័យ និងលំអិតអំពីការធ្វើបច្ចុប្បន្នភាព<br>- លំអិតអំពីការបណ្តុះបណ្តាល និងការធ្វើបច្ចុប្បន្នភាពជំនាញសម្រាប់អ្នកសំខាន់ៗដែលជាប់ទាក់ទង | បាទ<br>ទេ | ☐<br>☐ |
| | | | តើបានរៀបចំឲ្យមានប្រព័ន្ធគ្រប់គ្រងហានិភ័យឬទេ? | ផ្តល់សេចក្តីសម្រេច និង/ឬឯកសារពាក់ព័ន្ធនិងប្រព័ន្ធគ្រប់គ្រងវិបត្តិនៃទីក្រុង | បាទ<br>ទេ | ☐<br>☐ |

| | | |
|---|---|---|
| - ចំនួននៃសូចនករលំអិត÷ ៤<br>- ចំនួននៃលក្ខណៈវិនិច្ឆ័យ÷ ១២ | សរុប | ១២ |

## ៧)-តារាងវាយតម្លៃលើសូចនករចំនួន៥ នៃហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍

| សូចនករនៃហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍ | | តម្រូវការសម្រាប់លក្ខណៈវិនិច្ឆ័យសំខាន់ៗ | លក្ខណៈវិនិច្ឆ័យ | តស្តុតាងសម្រាប់លក្ខណៈវិនិច្ឆ័យ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|---|---|---|
| ១ | ផែនការសម្រាប់វិស័យទេសចរណ៍ | ភាពនៅមាននៃផែនការមេទេសចរណ៍ដែលកំពុងត្រូវបានអនុវត្ត និងឆ្លុះបញ្ចាំងបច្ចុប្បន្នភាពជាប្រចាំ | តើមានផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍សម្រាប់ទីក្រុងដែរ ឬទេ? | ផ្តល់សេចក្តីសម្រេច និង/ឬឯកសារពាក់ព័ន្ធទៅនិងផែនការមេទេសចរណ៍សម្រាប់ទីក្រុង | បាទ<br>ទេ | ☐<br>☐ |
| | | | តើផែនការមេត្រូវបានអនុវត្ត? | ផ្តល់ឈ្មោះអាជ្ញាធរ/ស្ថាប័នទទួលបន្ទុកលំអិតអំពីសកម្មភាពនិងវិធានការដែលបានដាក់ចេញដើម្បីអនុវត្តផែនការមេនេះ | បាទ<br>ទេ | ☐<br>☐ |
| | | | តើផែនការមេត្រូវបានត្រួតពិនិត្យនិងកែតម្រូវជាប្រចាំ (តិចបំផុតពីរឆ្នាំម្តង)? | ផ្តល់នូវឧបករណ៍ត្រួតពិនិត្យ / យន្តការតារាងពេល និងនិតិវិធីពិនិត្យឡើងវិញ (តិចបំផុតរៀងរាល់ពីរឆ្នាំ) | បាទ<br>ទេ | ☐<br>☐ |

| | | | | | | |
|---|---|---|---|---|---|---|
| ២ | **មណ្ឌលផ្តល់ព័ត៌មាន ស្លាកសញ្ញា និង ផែនទីទេសចរណ៍** | គុណភាពនៃមជ្ឈមណ្ឌលព័តមាន ផ្លាកសញ្ញា និងផែនទីទេសចរណ៍ | តើមានមណ្ឌលព័ត៌មានទេសចរណ៍ក្នុងទីក្រុង គ្រប់គ្រាន់ឬទេ? | ផ្តល់៖<br>- ផែនទី នៃមន្ទីរទេសចរណ៍ និងមជ្ឈមណ្ឌលព័តមានទេសចរណ៍ /ទីតាំងទេសចរណ៍<br>- អាជ្ញាធរទទួលបន្ទុក<br>- បុគ្គលិកដែលអាចទំនាក់ទំនងជាមួយទេសចរ<br>-ម៉ោងពេលធ្វើការ<br>- សម្ភារៈដែលមាន | មាន(តិចបំផុតមានមួយនៅតាមទីកន្លែងទេសចរណ៍សំខាន់ៗដើម្បីទទួលបាន១ពិន្ទុ)<br>មិនមាន | ☐<br>☐ |
| | | | តើកន្លែងទាក់ទាញទេសចរណ៍ក្នុងទីក្រុងត្រូវបានដាក់ស្លាកសញ្ញាសមរម្យឬទេ? | ផ្តល់ផែនទីចង្អុលបង្ហាញអំពីកន្លែងទាក់ទាញទេសចរណ៍ និងផ្លាកសញ្ញាបញ្ជាក់បង្ហាញអំពីទីតាំងផងដែរ (មានរូបថត ជាភស្តុតាង) | បាទ<br>ទេ | ☐<br>☐ |
| | | | តើមានស្លាកសញ្ញាជាភាសារអង់គ្លេសផងដែរ? | បង្ហាញភស្តុតាងអំពីភាសារអន្តរជាតិជាពិសេសភាសាអង់គ្លេសដែលត្រូវសរសេរនៅលើផ្លាកសញ្ញា (មានរូបថត ជាភស្តុតាង) | បាទ<br>ទេ | ☐<br>☐ |
| | | | តើមានផែនទីទេសចរណ៍សម្រាប់ទីក្រុង? | ផ្តល់នូវគំរូជាក់ស្តែងនៃផែនទីទេសចរណ៍សម្រាប់ទីក្រុង | បាទ<br>ទេ | ☐<br>☐ |
| | | | តើមានផែនទី និងព័ត៌មានទេសចរណ៍នានាដែលបានដាក់ចែកចាយ នៅកន្លែងទេសចរប្រមូលផ្តុំគ្នា ឬទេ? | បញ្ជាក់ភស្តុតាងអំពីសម្ភារៈ/មធ្យាបាយសម្រាប់ផ្សព្វផ្សាយ និងទីកន្លែងដែលទេសចរបានផ្តុំគ្នានៅក្នុងទីក្រុង (តារាងពេល/ភាពញឹកញាប់) | បាទ<br>ទេ | ☐<br>☐ |
| ៣ | **ទីតាំងនៃមជ្ឈមណ្ឌលលក់ឥវ៉ាន់ និង** | ភាពនៅបន្តមាននៃមជ្ឈមណ្ឌល | តើមានមជ្ឈមណ្ឌលលក់ឥវ៉ាន់និងហាងលក់ឥវ៉ាន់ក្នុងចម្ងាយស | ផ្តល់ផែនទីចង្អុលបង្ហាញអំពីទីតាំងមជ្ឈមណ្ឌលលក់ឥវ៉ាន់ ហាងលក់ឥវ៉ាន់ និងចម្ងាយផ្លូវទៅដល់ | បាទ<br>ទេ | ☐<br>☐ |

| | | | | | | |
|---|---|---|---|---|---|---|
| | **ហាងលក់រាយ** | លក់ឥវ៉ាន់ និងហាងលក់រាយ | មរម្យពីកន្លែងទេសចរប្រមូលផ្តុំគ្នាឬទេ?(កន្លែងទាក់ទាញទេសចរណ៍, សណ្ឋាគារ..) | ទីកន្លែងទេសចរណ៍ (កន្លែងទាក់ទាញទេសចរណ៍,សណ្ឋាគារ...) | | |
| | | | តើមានមជ្ឈមណ្ឌលសិប្បកម្មនៅជិតតំបន់ទេសចរណ៍ឬទេ? | ផ្តល់ផែនទីចង្អុលបង្ហាញអំពីទីតាំងនៃមជ្ឈមណ្ឌលសិប្បកម្ម (បញ្ជាក់អំពីទំហំផលិតផល...) និងចម្ងាយផ្លូវទៅដល់តំបន់ទេសចរណ៍ | បាទ<br>ទេ | ☐<br>☐ |
| | | | តើវត្ថុសិប្បកម្មដែលដាក់លក់មានគុណភាពល្អ និងជាវត្ថុតំណាងឲ្យទីក្រុងឬទេ? | បង្ហាញភស្តុតាងអំពីគុណភាព និងភាពដើម/អត្តសញ្ញាណនៃវត្ថុសិប្បកម្មដែលបានដាក់លក់ | បាទ<br>ទេ | ☐<br>☐ |
| | | | តើផលិតផលតំបន់បានដាក់លក់ឬទេ? | បង្ហាញភស្តុតាងអំពីវត្តមាននៃផលិតផលតំបន់ដែលដាក់លក់សម្រាប់ទេសចរ (បញ្ជាក់ច្បាស់អំពីប្រភេទនៃផលិតផលទីតាំងនៃហាងទំនិញ...) | បាទ<br>ទេ | ☐<br>☐ |
| ៤ | **តំបន់សម្រាកលំហែ (តំបន់ទេសចរណ៍ ឧទ្យាន សាធារណៈ កីឡា និងការកំសាន្ត** | ភាពនៅបន្តមាន និងការចង្អុលបង្ហាញនៃតំបន់លំហែរ | តើកន្លែងកំសាន្តក្នុងទីក្រុងត្រូវបានចង្អុល បង្ហាញច្បាស់លាស់ និងប្រើប្រាស់បាន សម្រាប់ទេសចរ? | បង្ហាញភស្តុតាងនៃភាពនៅមាននៃតំបន់លំហែរក្នុងទីក្រុង ជាមួយនិងផែនទីចង្អុលបង្ហាញអំពីទីតាំងនៃតំបន់លំហែរទាំងនោះ(បង្ហាញភស្តុតាងនៃផ្លាកសញ្ញាតំបន់លំហែរទាំងនោះ) | បាទ<br>ទេ | ☐<br>☐ |
| | | | តើប្រជាជនអាចទៅលេងកំសាន្តបាន ឬទេ? | ផ្តល់លំដាប់នៃតម្លៃ ថាតើអាចមានលទ្ធភាពសម្រាប់ប្រជាជនក្នុងតំបន់ ឬទេ(មានតម្លៃពិសេសណា សម្រាប់ជាជនក្នុងតំបន់ ឬទេ?) | បាទ<br>ទេ | ☐<br>☐ |
| ៥ | **កំរិតនៃការពេញចិត្តរបស់ភ្ញៀវទេសចរណ៍** | ភាពនៅមានបន្តនៃការស្ទង់មតិដែលបានធ្វើដើម្បីបញ្ជាក់ | តើមានធ្វើការស្ទង់មតិជាប្រចាំឬទេដើម្បីវាស់ស្ទង់អំពីកម្រិត | បង្ហាញភស្តុតាងៈ<br>-ប្រភេទនៃការស្ទង់មតិដែលបានធ្វើឡើង | បាទ<br>ទេ | ☐<br>☐ |

| | | | | | | |
|---|---|---|---|---|---|---|
| | | អំពីការពេញចិត្តរបស់ទេសចរ | នៃការពេញចិត្តរបស់ទេសចរលើភាពស្អាត ការស្វាគមន៍ និងបដិសណ្ឋាកិច្ច សន្តិសុខ និងការឲ្យតម្លៃអំពីការតុបតែងនិងបរិស្ថាននៃទីក្រុង? | -ចំពោះគោលដៅ(ទេសចរក្នុងស្រុក និងទេសចរអន្តរជាតិ)<br>-គោលបំណងនៃការស្ទង់មតិ<br>-តារាងពេល/ញឹកញាប់យ៉ាងណា | | |
| | | | តើទេសចរប៉ុន្មានភាគរយមានការពេញចិត្ត? | ផ្តល់លទ្ធផល (ស្ថិតិ) នៃការស្ទង់មតិដែលបានធ្វើឡើងថ្មីៗកន្លងមក ដើម្បីវាស់ស្ទង់អំពីភាពពេញចិត្តរបស់ទេសចរ | ____(តិចបំផុត៧0% មានការពេញចិត្តដើម្បីទទួលបាន១ពិន្ទុ) | |
| | | | តើបានធ្វើការស្ទង់មតិញឹកញាប់កម្រិតណា? | ផ្តល់តារាងពេលនៃការស្ទង់មតិដើម្បីបញ្ជាក់ភស្តុតាងអំពីភាពញឹកញាប់ | មួយឆ្នាំម្តង ឬច្រើនជាង (តិចបំផុតរៀងរាល់ឆ្នាំដើម្បីទទួលបាន១ពិន្ទុ)<br>តិចជាង១ដងក្នុង១ឆ្នាំ | ☐<br>☐ |
| | | | តើលទ្ធផលពីការស្ទង់មតិបានដាក់ចេញជាសកម្មភាពដើម្បីពង្រឹងស្ថានភាពឲ្យកាន់តែប្រសើរឡើង ឬទេ? | បង្ហាញភស្តុតាងអំពីការអនុវត្តន៍នៃសកម្មភាព/វិធានការ ផ្អែកលើលទ្ធផលនៃការស្ទង់មតិដើម្បីពង្រឹងស្ថានភាពឲ្យកាន់តែប្រសើរឡើង (អាជ្ញាធរទទួលបន្ទុក, ប្រភេទនៃសកម្មភាព/វិធានការ...) | បាទ<br>ទេ | ☐<br>☐ |
| **- ចំនួននៃសូចនករលំអិត÷ ៥**<br>**- ចំនួននៃលក្ខណៈវិនិច្ឆ័យ÷ ១៨** | | | | | **សរុប** | **១៨** |